ជូនចំពោះអ្នកជំងឺរបស់ APHCV ៖

យើងកំពុងសរសេរទៅអ្នកដើម្បីប្រាប់អោយអ្នកដឹងថា មជ្ឈមណ្ឌលថែទាំសុខភាពសហគមន៍អេសៀនប៉ាស៊ីហ្វិក ហ៊ើលយែរវែនឈ័រអ៊ិនស៍(APHCV) នៅតែបន្តផ្តល់សេវាគ្លីនិក ដល់អ្នកជំងឺរបស់យើង ទោះបីជាមានស្ថានភាពអំពីខូវីត-១៩(Coronavirus) នាពេលបច្ចុប្បន្នក៏ដោយ។ អាទិភាពចំបងរបស់យើងគឺសុខមាលភាពអ្នកជំងឺរបស់យើង បុគ្គលិករបស់យើងនិងសហគមន៍ទាំងអស់។ ដូច្នេះហើយ យើងកំពុងតាមដានយ៉ាងជិតដល់នូវការវិវឌ្ឍន៍ចុងក្រោយរបស់ខូវីត-១៩។

ដើម្បីការពារអ្នក គ្រួសាររបស់អ្នកនិងបុគ្គលិករបស់យើង ឥឡូវនេះ APHCV កំពុងផ្តល់សេវាកម្មណាត់ជួបតាមទូរស័ព្ទ វាជាមធ្យោបាយដែលអ្នកទទួលបានការប្រឹក្សាយោបល់ផ្នែកសុខភាពដោយផ្ទាល់ពីគ្រូពេទ្យរបស់យើងតាមរយៈទូរស័ព្ទ។ ដើម្បីដាក់ណាត់ជាមួយគ្រូពេទ្យរបស់យើង សូមទូរស័ព្ទមកកាន់ (323)644-3888។ យើងក៏កំពុងទូរស័ព្ទទៅកាន់អ្នកជំងឺដែលអាចមានហានិភ័យខ្ពស់ក្នុងការឆ្លងវីរុសខូវីត-១៩។ យើងពិតជាចង់ទំនាក់ទំនងជាមួយអ្នកដើម្បីសុខុមាលភាពរបស់អ្នក។

នៅពេលដែលគ្រូពេទ្យស្នើសុំឱ្យអ្នកមកកាន់ទីតាំងមណ្ឌលសុខភាពរបស់យើងដោយផ្ទាល់ យើងនឹងសួរអ្នកនូវសំនួរដែលទាក់ទងនឹងខូវីត-១៩។ យើងនឹងឱ្យនរណាម្នាក់សួរសំណួរទាំងនោះទៅកាន់អ្នកជំងឺទាំងអស់របស់យើង និងភ្ញៀវទាំងអស់នៅច្រកទ្វារចូល។ APHCV សូមអរគុណចំពោះការសហការណ៍និងការយោគយល់របស់អ្នក។

បច្ចុប្បន្ននេះ APHCV មិនមានផ្តល់ជូននូវការធ្វើតេស្តរកខូវីត-១៩ នៅតាមទីតាំងរបស់យើងនោះទេ។ យោងតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលមូលដ្ឋាន ពេលដែលអ្នកចាំបាច់ត្រូវការធ្វើតេស្ត យើងនឹងធ្វើការបញ្ជូនអ្នកអោយបានសមស្រប។ ប្រសិនបើ/នៅពេលដែលយើងចាប់ផ្តើមផ្តល់ការធ្វើតេស្ត យើងនឹងផ្តល់ដំណឹងជូនអ្នកភ្លាមៗ។

ដោយក្តីស្មោះត្រង់,

ក្រុមថែរក្សាសុខភាពរបស់ APHCV